

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

CIAS 24

ការលាតត្រដាងពីភាគីពាក់ព័ន្ធ

Related Party Disclosures

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

អារម្ភកថា

ដោយសារនយោបាយ "**ឈ្នះ-ឈ្នះ**" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបានន្ូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទ្ូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងន្ូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ន្ូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**", "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**", "**យុទ្ធសាស្ត្រត្រីកោណ**", "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**" និង "**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**" ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និង**ក្រុមប្រឹក្សាជាតិគណនេយ្យ** ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតន្ូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ជាត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី "**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា**" ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបានន្ូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ពន្ធ៍ទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ពន្ធ៍នៃ “**យុទ្ធសាស្ត្រអភិវឌ្ឍន៍ទីសំយកហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**” របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **អ៊ឹ តាយ៉ី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

អារម្ភកថា

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**"។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី "គណនេយ្យ សហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ" នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន" *ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* " និង *"ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសខ្នាតតូចនិងមធ្យម"* ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.ស-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍនភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥

រដ្ឋលេខាធិការ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា

ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ

ង៉ី ស៊ាយ៉ី

គោលបំណង

๑ គោលបំណងនៃស្តង់ដានេះ គឺដើម្បីធានាថារបាយការណ៍របស់អង្គភាពបានបញ្ចូលការលាតត្រដាង ដែលចាំបាច់ ដើម្បីទាញការចាប់អារម្មណ៍ចំពោះភវនីយភាពដែលរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនិងរបាយការណ៍ចំណេញ ឬខាត អាចរងផលប៉ះពាល់ពីការកើតមានឡើងនៃភាគីពាក់ព័ន្ធ និងរងផលប៉ះពាល់ពីប្រតិបត្តិការ និងសមតុល្យនៅសល់ រួមបញ្ចូលការសន្យាទាំងឡាយ ជាមួយភាគីទាំងអស់នោះ។

វិសាលភាព

๒ ស្តង់ដានេះត្រូវបានអនុវត្តនៅក្នុង:

(ក) ការកំណត់អត្តសញ្ញាណពីទំនាក់ទំនងភាគីពាក់ព័ន្ធនិងប្រតិបត្តិការ

(ខ) ការកំណត់អត្តសញ្ញាណពីសមតុល្យនៅសល់ រួមបញ្ចូលទាំងការសន្យាទាំងឡាយ រវាងអង្គភាពមួយ និង ភាគីពាក់ព័ន្ធរបស់គេ។

(គ) ការកំណត់អត្តសញ្ញាណពីកាល:ទេស:ទាំងឡាយ ដែលការលាតត្រដាងនៃធាតុនៅក្នុង (ក) និង (ខ) ត្រូវបានតម្រូវឱ្យមាន និង

(ឃ) ការកំណត់ពីការលាតត្រដាងទាំងឡាយដែលត្រូវធ្វើអំពីធាតុទាំងនោះ។

៣ ស្តង់ដានេះ តម្រូវឱ្យមានការលាតត្រដាងពី ទំនាក់ទំនងប្រតិបត្តិការ និង សមតុល្យនៅសល់របស់ ភាគីពាក់ព័ន្ធ រួមបញ្ចូលទាំងការសន្យានៅក្នុង របាយការណ៍ហិរញ្ញវត្ថុរួមនិងដាច់ដោយឡែករបស់ក្រុមហ៊ុនមេ ក្រុមហ៊ុន រួមទុន ឬក្រុមហ៊ុនទិញវិនិយោគដែលបានដាក់បង្ហាញដោយអនុលោមតាម ស.គ.អ.ក ២៧ *របាយការណ៍ហិរញ្ញវត្ថុរួមនិងដាច់ដោយឡែក*។ ស្តង់ដា នេះក៏អនុវត្តផងដែរចំពោះរបាយការណ៍ការហិរញ្ញវត្ថុមួយៗ។

៤ ប្រតិបត្តិការ និងសមតុល្យនៅសល់របស់ភាគីពាក់ព័ន្ធជាមួយនឹងអង្គភាព ផ្សេងទៀតនៅក្នុងបណ្តុំក្រុមហ៊ុនត្រូវបានលាតត្រដាងនៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុរបស់អង្គភាព។ ប្រតិបត្តិការខាងក្នុងបណ្តុំក្រុមហ៊ុន របស់ភាគី ពាក់ព័ន្ធ និងសមតុល្យនៅសល់ ត្រូវបានលុបចោលនៅក្នុងការរៀបចំ របាយការណ៍ហិរញ្ញវត្ថុរួម និង ដាច់ដោយឡែករបស់បណ្តុំក្រុមហ៊ុន។

គោលបំណងនៃការលាតត្រដាងពីភាគីពាក់ព័ន្ធ

៥ ទំនាក់ទំនងរបស់ភាគីពាក់ព័ន្ធ គឺជាលក្ខណៈធម្មតា នៃពាណិជ្ជកម្ម និង អាជីវកម្ម។ ឧទាហរណ៍ អង្គភាពជាញឹកញាប់ប្រតិបត្តិផ្នែកមួយចំនួននៃ សកម្មភាពរបស់គេតាមរយៈ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនរួមទុន និង ក្រុមញាតិសម្ព័ន្ធ។ នៅក្នុងកាលៈទេសៈទាំងនោះ អង្គភាពមានលទ្ធភាព ដើម្បីធ្វើឱ្យប៉ះពាល់ដល់គោល នយោបាយហិរញ្ញវត្ថុនិងប្រតិបត្តិការរបស់ ក្រុមហ៊ុន លក់ការវិនិយោគតាមរយៈវត្តមាននៃការគ្រប់គ្រង គ្រប់គ្រងរួម ឬឥទ្ធិពលសំខាន់។

៦ ទំនាក់ទំនងរបស់ភាគីពាក់ព័ន្ធអាចមានឥទ្ធិពលលើរបាយការណ៍ចំណេញ ឬខាត និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព។ ភាគីពាក់ព័ន្ធ អាចមានប្រតិបត្តិការដែលភាគីមិនពាក់ព័ន្ធមិនមាន។ ឧទាហរណ៍ អង្គភាពមួយដែលលក់ទំនិញទៅឱ្យក្រុមហ៊ុនមេរបស់ខ្លួនតាមថ្លៃដើមអាចមិនលក់តាមលក្ខខណ្ឌទាំង នេះទៅឱ្យអតិថិជនផ្សេងទៀត។ ប្រតិបត្តិការរវាងភាគីពាក់ព័ន្ធ អាចមិនត្រូវបានធ្វើឡើងតាមទឹកប្រាក់ដូចគ្នានឹងភាគីមិនពាក់ព័ន្ធ។

៧ របាយការណ៍ចំណេញ ឬខាត និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពអាចរងផលប៉ះពាល់ដោយ ទំនាក់ទំនងរបស់ភាគីពាក់ពន្ធ ទោះបីជាប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធមិនកើតឡើងក៏ដោយ។ ការកើតមានឡើងតែទំនាក់ទំនងអាចគ្រប់គ្រាន់ដើម្បីធ្វើឱ្យប៉ះពាល់ប្រតិបត្តិការរបស់អង្គភាពជាមួយភាគីផ្សេងទៀត។ ជាឧទាហរណ៍ ក្រុមហ៊ុនបុត្រសម្ព័ន្ធអាចបញ្ឈប់ទំនាក់ទំនងជាមួយដៃគូរជួញដូរលើការទិញដោយក្រុមហ៊ុនរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធដូចគ្នាដែលមានសកម្មដូចគ្នានឹងអតីតដៃគូជួញដូរ។ ជាជម្រើសភាគីមួយអាចទប់ស្កាត់ពីការប្រតិបត្តិ ដោយសារតែឥទ្ធិពលសំខាន់របស់ភាគីមួយទៀត ជាឧទាហរណ៍ អង្គភាពមួយអាចត្រូវបានណែនាំដោយក្រុមហ៊ុនមិនឱ្យជាប់ពាក់ព័ន្ធក្នុងការស្រាវជ្រាវនិងការអភិវឌ្ឍ។

៨ សម្រាប់ហេតុផលទាំងនេះការយល់ដឹងពីប្រតិបត្តិការរបស់អង្គភាពសមតុល្យ នៅសល់ រួមបញ្ចូលទាំងការសន្យា និង ទំនាក់ទំនងជាមួយភាគីទាក់ទិន អាចប៉ះពាល់ដល់ការវាយតម្លៃ នៃប្រតិបត្តិការដោយអ្នកប្រើ

របាយការណ៍ ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការវាយតម្លៃពីហានិភ័យនិងឱកាស ដែលប្រឈមចំពោះអង្គភាព ។

និយមន័យ

៩ វាក្យសំព្ទខាងក្រោមនេះ ត្រូវបានប្រើនៅក្នុងស្តង់ដានេះជាមួយនឹងអត្ថន័យ ដូចតទៅ:

ភាគីពាក់ព័ន្ធ គឺជាបុគ្គល ឬអង្គភាពដែលមានការពាក់ព័ន្ធ ចំពោះអង្គភាព ដែលកំពុងរៀបចំ របាយការណ៍ហិរញ្ញវត្ថុ (នៅក្នុងស្តង់ដានេះត្រូវបាន ហៅថា "អង្គភាពរាយការណ៍")។

(ក) បុគ្គលម្នាក់ ឬសមាជិកជិតស្និត នៃគ្រួសាររបស់បុគ្គលនោះមានការ ពាក់ព័ន្ធចំពោះអង្គភាព រាយការណ៍ ប្រសិនបើបុគ្គលនោះ :

(១) មានការគ្រប់គ្រង ឬការគ្រប់គ្រងរួម លើអង្គភាពរាយ-ការណ៍

(២) មានឥទ្ធិពលសំខាន់លើអង្គភាពរាយការណ៍ ឬ

(៣) ជាសមាជិកនៃបុគ្គលិកគ្រប់គ្រងសំខាន់នៃអង្គភាពរាយ-ការណ៍ ឬនៃក្រុមហ៊ុនមេរបស់អង្គភាពរាយការណ៍

(ខ) អង្គភាពមួយ មានការពាក់ព័ន្ធ ចំពោះអង្គភាពរាយការណ៍ប្រសិនបើ លក្ខខណ្ឌណាមួយនៃលក្ខខណ្ឌខាងក្រោមប្រើ:

(១) អង្គភាព និងអង្គភាពរាយការណ៍ គឺជាសមាជិកនៃបណ្តុំក្រុមដូចគ្នា (ដែលមានន័យថាក្រុមហ៊ុនមេ ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងក្រុមហ៊ុនបុត្រសម្ព័ន្ធដូចគ្នានីមួយៗ) មានការពាក់ព័ន្ធនឹងក្រុមហ៊ុន ផ្សេងទៀត។

(២) អង្គភាពមួយគឺជាក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុនរបស់អង្គភាពផ្សេងទៀត (ឬជាក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុនរបស់សមាជិកនៃបណ្តុំក្រុមហ៊ុនដែលអង្គភាពផ្សេងទៀតគឺជាសមាជិក)។

(៣) អង្គភាពទាំងពីរគឺជាក្រុមហ៊ុនរួមទុននៃភាគីទី៣ដូចគ្នា។

(៤) ភាគីមួយ គឺជាក្រុមហ៊ុនរួមទុននៃអង្គភាពទី៣ ហើយអង្គភាពផ្សេងទៀត គឺជាក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ នៃអង្គភាពទី៣

(៥) អង្គភាពគឺជាផែនការអត្ថប្រយោជន៍ក្រោយការងារសម្រាប់ អត្ថប្រយោជន៍របស់និយោជិកនៃអង្គភាពរាយការណ៍ ឬ អង្គភាពដែលទាក់ទងនឹងអង្គភាពរាយការណ៍។ ប្រសិន បើអង្គភាពរាយការណ៍ គឺជាអង្គភាពផែនការខ្លួនឯងនោះ និយោជក ដែលឧបត្ថម្ភគឺជាភាគីពាក់ព័ន្ធផងដែរទៅនឹង អង្គភាពរាយការណ៍។

(៦) អង្គភាពត្រូវបានគ្រប់គ្រង ឬត្រូវបានគ្រប់គ្រងរួមដោយបុគ្គល ដែលបានកំណត់អត្តសញ្ញាណ នៅក្នុង (ក)។

(៧) បុគ្គលដែលបានកំណត់អត្តសញ្ញាណនៅក្នុង(ក)(១)មាន ឥទ្ធិពលសំខាន់លើអង្គភាព ឬគឺជា សមាជិកនៃបុគ្គលិក គ្រប់គ្រងសំខាន់របស់អង្គភាព (ឬនៃក្រុមហ៊ុនមេនៃអង្គ-ភាព)។

ប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ គឺជាការផ្ទេរនៃធនធាន សេវាកម្ម ឬកាតព្វ-កិច្ចរវាងអង្គភាពរាយការណ៍ និងភាគីពាក់ព័ន្ធ ដោយមិនគិតថាតើតម្លៃ ត្រូវបានដាក់បន្ទុកនោះទេ។

សមាជិកជិតស្និទ្ធនៃគ្រួសាររបស់បុគ្គល គឺជាសមាជិកគ្រួសារទាំងឡាយ ណាដែលអាចត្រូវបានរំពឹងទុកថា នឹងមានឥទ្ធិពល ឬរងឥទ្ធិពល ដោយ បុគ្គលនោះនៅក្នុងការជាប់ពាក់ព័ន្ធជាមួយនឹងអង្គភាព និង រួមបញ្ចូល:

(ក) កូនរបស់បុគ្គល និង ប្តីប្រពន្ធ ឬ ដៃគូក្នុងប្រទេស

(ខ) កូនរបស់ប្តីប្រពន្ធរបស់បុគ្គល ឬ ដៃគូក្នុងប្រទេស និង

(គ) បុគ្គលរងការទំនុកបំរុងពីប្តីប្រពន្ធរបស់បុគ្គលនោះឬដៃគូរក្នុងស្រុក

តម្លៃតបស្នង បញ្ចូលនូវអត្ថប្រយោជន៍និយោជិកទាំងអស់ (ដូចបានកំណត់ នៅក្នុង ស.គ.អ.ក ១៩ *អត្ថប្រយោជន៍និយោជិក)* រួមបញ្ចូលទាំងអត្ថ-ប្រយោជន៍និយោជិកដែល ស.រ.ហ.អ.ក ២ *ការទូទាត់ផ្អែកលើភាគហ៊ុន* អនុវត្ត។ អត្ថប្រយោជន៍និយោជិកជាទំរង់ទាំងអស់នៃតម្លៃតបស្នងបានបង់ ត្រូវបង់ ឬបានផ្តល់ដោយអង្គភាព ឬជំនួសដោយអង្គភាព ក្នុងការដោះដូរ ចំពោះសេវាដែលបានផ្តល់ទៅឱ្យអង្គភាព។ អត្ថប្រយោជន៍ក៏បញ្ចូលតម្លៃ

តបស្នងដែលបានបង់ជំនួសឱ្យក្រុមហ៊ុនមេរបស់អង្គភាពដែលទាក់ទងនឹងក្រុមហ៊ុន។ តម្លៃតបស្នងបញ្ចូល:

(ក) អត្ថប្រយោជន៍និយោជិករយៈពេលខ្លី ដូចជាប្រាក់ឈ្នួល ប្រាក់ខែ និងវិភាគទានសន្តិសុខសង្គម ការឈប់សម្រាកប្រចាំឆ្នាំដែលបង់រួច និងការឈប់សម្រាកឈឺដែលបង់រួច ការចែកប្រាក់ចំណេញ ឬប្រាក់បន្ថែម (ប្រសិនបើត្រូវបង់ក្នុងរយៈពេល ១២ខែ នៃចុងការិយ-បរិច្ឆេទ) និង អត្ថប្រយោជន៍មិនមែនហិរញ្ញវត្ថុ (ដូចជាការថែទាំសុខភាព ការផ្តល់ លំនៅដ្ឋាន រថយន្ត និងទំនិញឬសេវាមិនគិតថ្លៃ ឬឧបត្ថម្ភធន) សម្រាប់ និយោជិកបច្ចុប្បន្ន

(ខ) អត្ថប្រយោជន៍ក្រោយការងារដូចជាប្រាក់សោធននិវត្តន៍អត្ថប្រយោជន៍ចូលនិវត្តន៍ផ្សេងទៀត ធានារ៉ាប់រងជីវិតក្រោយការងារ និងការថែទាំសុខភាពក្រោយការងារ

(គ) អត្ថប្រយោជន៍និយោជិករយៈពេលវែងផ្សេងទៀត រួមបញ្ចូលនូវការឈប់សម្រាក សម្រាប់សេវារយៈពេលវែង ឬការឈប់សម្រាកប្រចាំឆ្នាំ

អត្ថប្រយោជន៍សម្រាប់សេវារយៈពេលផ្សេងទៀតឬបុណ្យអត្ថប្រយោជន៍ ពិការភាពរយៈពេលវែង និងប្រសិនបើអត្ថប្រយោជន៍ទាំងនោះមិនត្រូវបង់ទាំងអស់ នៅក្នុងរយៈពេល ១២ខែ បន្ទាប់ពីចុងការិយបរិច្ឆេទការចែកប្រាក់ចំណេញ ប្រាក់បន្ថែម និងតម្លៃតបស្នងពន្យា

(ឃ) អត្ថប្រយោជន៍បញ្ឈប់ពីការងារ និង

(ង) ការទូទាត់ផ្អែកលើភាគហ៊ុន។

គ្រប់គ្រង គឺជាអំណាចដើម្បីគ្រប់គ្រងគោលនយោបាយប្រតិបត្តិការ និងហិរញ្ញវត្ថុរបស់អង្គភាពមួយ ដើម្បីទទួលអត្ថប្រយោជន៍ពីសកម្មភាពរបស់ខ្លួន។

ការគ្រប់គ្រងរួម គឺជាចែកការគ្រប់គ្រងដែលបានយល់ព្រមតាមកិច្ចសន្យាលើសកម្មភាពសេដ្ឋកិច្ច។

បុគ្គលិកគ្រប់គ្រងសំខាន់ គឺជាបុគ្គលទាំងឡាយដែលមានសិទ្ធិអំណាច និងការទទួលខុសត្រូវ ក្នុងការធ្វើផែនការ ដឹកនាំការងារ និងត្រួតពិនិត្យសកម្មភាពរបស់អង្គភាពដោយផ្ទាល់ឬដោយប្រយោលរួមបញ្ចូលនូវនាយកណាមួយ (ថាតើជានាយកប្រតិបត្តិ ឬ មិនប្រតិបត្តិ) នៃអង្គភាពនោះ។

ឥទ្ធិពលសំខាន់ គឺជាអំណាចដើម្បីចូលរួមនៅក្នុងការសំរេចគោលនយោ-បាយ ប្រតិបត្តិការ និងហិរញ្ញវត្ថុរបស់អង្គភាព ប៉ុន្តែមិនគ្រប់គ្រងលើគោលនយោបាយទាំងនោះទេ។ ឥទ្ធិពលសំខាន់ អាចត្រូវបានទទួលដោយការកាន់កាប់ភាគហ៊ុន លក្ខន្តិកៈ ឬកិច្ចព្រមព្រៀង។

រដ្ឋាភិបាល សំដៅលើរដ្ឋាភិបាល ភ្នាក់ងាររដ្ឋាភិបាល និងអង្គភាពស្រដៀងគ្នាថាតើថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ឬថ្នាក់អន្តរជាតិទេ។

អង្គភាពពាក់ព័ន្ធនឹងរដ្ឋាភិបាល គឺជាអង្គភាពមួយដែលត្រូវបានគ្រប់គ្រង ឬរងការគ្រប់គ្រងរួម ឬរងឥទ្ធិពលសំខាន់ដោយរដ្ឋាភិបាល។

១០ នៅក្នុងការពិចារណាពីទំនាក់ទំនងរបស់ភាគីពាក់ព័ន្ធ ដែលអាចកើតមាននីមួយៗ ការយកចិត្តត្រូវបានសំដៅ ទៅលើស្ថានភាពពិតនៃទំនាក់ទំនង និង មិនមើលតែទៅលើទំរង់ច្បាប់ទេ។

១១ នៅក្នុងបរិការណ៍នៃស្តង់ដានេះ ខាងក្រោមគឺមិនមែនជាភាគីពាក់ព័ន្ធទេ:

(ក) អង្គភាពពីរជាធម្មតា ដោយសារតែអង្គភាពនោះមាននាយក ឬសមាជិកនៃបុគ្គលិកគ្រប់គ្រងសំខាន់ៗជារួមឬដោយសារសមាជិកមួយនៃបុគ្គលិកគ្រប់គ្រងសំខាន់ នៃអង្គភាពមួយ មានឥទ្ធិពលសំខាន់លើអង្គភាពមួយផ្សេងទៀត។

(ខ) អ្នកចូលរួមទុនពីរនាក់ជាធម្មតា ពីព្រោះពួកគេចែកការគ្រប់គ្រងរួមលើក្រុមហ៊ុនរួមទុន។

(គ) (១) ស្ថាប័នផ្តល់ហិរញ្ញវត្ថុ

(២) សហជីពពាណិជ្ជកម្ម

(៣) អង្គភាពសាធារណៈ

(៤) នាយកដ្ឋាន និងភ្នាក់ងាររបស់រដ្ឋាភិបាល ដែលមិនគ្រប់គ្រង គ្រប់គ្រងរួម ឬមានឥទ្ធិពលសំខាន់ លើអង្គភាពរាយការណ៍

ជាធម្មតាដោយភាពត្រឹមត្រូវនៃការពាក់ព័ន្ធជាប្រក្រតីជាមួយអង្គភាព (ទោះបីជា អង្គភាពអាចធ្វើឱ្យប៉ះពាល់ដល់ សេរីភាពនៃសកម្មភាពរបស់អង្គភាព ឬចូលរួមនៅក្នុងដំណើរការនៃការសំរេចចិត្ត)។

(ឃ) អតិថិជន អ្នកផ្គត់ផ្គង់ អ្នកលក់សិទ្ធិពិសេស អ្នកចែកចាយ ឬភ្នាក់ងារទូទៅ ជាមួយនឹងអង្គភាព ដែលមានប្រតិបត្តិការទំហំអាជីវកម្មធំ ជាធម្មតាដោយភាពត្រឹមត្រូវនៃអនិស្សរភាពសេដ្ឋកិច្ច

១២ នៅក្នុងនិយមន័យភាគីពាក់ព័ន្ធ ក្រុមហ៊ុនញាតិសម្ព័ន្ធរួមបញ្ចូលនូវក្រុមហ៊ុនបុត្រសម្ព័ន្ធ នៃក្រុមហ៊ុនញាតិសម្ព័ន្ធ និងក្រុមហ៊ុនរួមទុនរួមបញ្ចូលក្រុមហ៊ុនបុត្រសម្ព័ន្ធនៃក្រុមហ៊ុនរួមទុន។ ដូច្នេះ ជាឧទាហរណ៍ ក្រុមហ៊ុនបុត្រសម្ព័ន្ធនៃក្រុមហ៊ុនញាតិសម្ព័ន្ធ និងក្រុមហ៊ុនទិញការវិនិយោគដែលមានឥទ្ធិពលសំខាន់លើ ក្រុមហ៊ុនញាតិសម្ព័ន្ធមានការពាក់ព័ន្ធរវាងគ្នានិងគ្នា។

ការលាតត្រដាង

អង្គភាពទាំងអស់

១៣ ទំនាក់ទំនងរវាងក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានលាតត្រដាងដោយមិនគិតថាតើមានប្រតិបត្តិការរវាងក្រុមហ៊ុនទាំងពីរខាងលើនោះទេ។ អង្គភាពមួយត្រូវលាតត្រដាងពីឈ្មោះរបស់អង្គភាពក្រុមហ៊ុនមេនិងប្រសិនបើខុស ត្រូវលាតត្រដាងពីភាគីគ្រប់គ្រងចុងក្រោយ។ ប្រសិនបើទាំងក្រុមហ៊ុនមេរបស់អង្គភាព និងទាំងភាគីគ្រប់គ្រងចុងក្រោយមិនផលិតរបាយ-ការណ៍ហិរញ្ញវត្ថុសម្រាប់ការប្រើប្រាស់ជាសាធារណៈ នោះឈ្មោះនៃក្រុមហ៊ុន មេជាន់ខ្ពស់បំផុតបន្ទាប់ ដែលផលិតរបាយការណ៍ហិរញ្ញវត្ថុក៏ត្រូវលាតត្រដាងបង្ហាញផងដែរ ។

១៤ ដើម្បីឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ អាចបង្កើតទស្សនៈអំពីឥទ្ធិពលពីទំនាក់ទំនងភាគីពាក់ព័ន្ធមកលើអង្គភាពមួយ វាមានភាពត្រឹមត្រូវ ដើម្បីលាតត្រដាងពី ទំនាក់ទំនងភាគីពាក់ព័ន្ធ នៅពេលការគ្រប់គ្រងកើតមានឡើង ដោយមិនគិតថាតើមានប្រតិបត្តិការរវាងភាគីពាក់ព័ន្ធទេ។

១៥ សេចក្តីតម្រូវ ដើម្បីលាតត្រដាងពីទំនាក់ទំនងភាគីពាក់ព័ន្ធរវាងក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធគឺជាការបន្ថែមចំពោះសេចក្តីតម្រូវពីការលាតត្រដាង នៅក្នុង ស.គ.អ.គ ២៧ ស.គ.អ.ក ២៨ *ការវិនិយោគនៅក្នុង ក្រុមហ៊ុន ញាតិសម្ព័ន្ធ* និង ស.គ.អ.ក ៣១ *ភាគកម្មអប្បភាគនៅក្នុងក្រុមហ៊ុនរួមមនុន*។

១៦ កថាខណ្ឌ ១៣ សំដៅដល់ក្រុមហ៊ុនមេជាន់ខ្ពស់បំផុតបន្ទាប់។ នេះគឺជាក្រុមហ៊ុនមេលើកដំបូង នៅក្នុងបណ្តុំក្រុមហ៊ុនខាងលើ ក្រុមហ៊ុនមេផ្តាល់ដែលផលិតរបាយការណ៍ហិរញ្ញវត្ថុរួមសម្រាប់ប្រើប្រាស់ជាសាធារណៈ។

១៧ អង្គភាពមួយ ត្រូវលាតត្រដាងពី តម្លៃតបស្នងបុគ្គលិកគ្រប់គ្រងសំខាន់ៗ នៅក្នុងតម្លៃសរុប និងសម្រាប់ខ្ទង់ នីមួយៗដូចខាងក្រោម:

(ក) អត្ថប្រយោជន៍និយោជិករយៈពេលខ្លី

(ខ) អត្ថប្រយោជន៍ក្រោយការងារ

(គ) អត្ថប្រយោជន៍រយៈពេលវែងផ្សេងទៀត

(ឃ) អត្ថប្រយោជន៍បញ្ឈប់ពីការងារ

(ង) ការទូទាត់ផ្អែកលើភាគហ៊ុន

១៨ ប្រសិនបើអង្គភាពមួយមានប្រតិបត្តិការភាគីពាក់ព័ន្ធក្នុងកំឡុងការិយបរិច្ឆេទដែលគ្របដណ្តប់ ដោយរបាយការណ៍ហិរញ្ញវត្ថុ នោះអង្គភាព ត្រូវលាតត្រដាងពីលក្ខណៈនៃទំនាក់ទំនងរបស់ភាគីពាក់ព័ន្ធក៏ដូចជា ព័ត៌មានអំពីប្រតិបត្តិការទាំងនោះនិងសមតុល្យនៅសល់រួមបញ្ចូលការសន្យា ដែលចាំបាច់សម្រាប់អ្នកប្រើប្រាស់ ដើម្បីយល់បានពី ឥទ្ធិពលនៃទំនាក់ទំនងលើ

របាយការណ៍ហិរញ្ញវត្ថុ។ សេចក្តីតម្រូវពីការលាតត្រដាងទាំងនេះ គឺជាការបន្ថែមចំពោះសេចក្តីតម្រូវមាននៅក្នុងកថាខណ្ឌ១៧។ ជាអប្បរមាការលាតត្រដាងត្រូវបញ្ចូលនូវ:

(ក) ទឹកប្រាក់នៃប្រតិបត្តិការ

(ខ) ទឹកប្រាក់នៃសមតុល្យនៅសល់ រួមបញ្ចូលការសន្យា និង

(ឧ) លក្ខខណ្ឌរបស់គ្រួសបញ្ចូល ថាតើលក្ខខណ្ឌទាំងនោះ ត្រូវបានធានា និងលក្ខណៈនៃតម្លៃតបស្នងដែលនឹងត្រូវផ្តល់ នៅក្នុងការទូទាត់ និង

(ឩ) សេចក្តីលំអិតនៃការធានាដែលបានផ្តល់ ឬ បានទទួល

(គ) សំវិធានធន សម្រាប់បំណុលសង្ស័យ ដែលទាក់ទិននឹងទឹកប្រាក់នៃសមតុល្យនៅសល់ និង

(ឃ) ចំណាយដែលបានទទួលស្គាល់ក្នុងកំឡុងការិយបរិច្ឆេទ ដែលទាក់ទិននឹងបំណុលអាក្រក់ ឬសង្ស័យជំពាក់ពីភាគីពាក់ព័ន្ធ។

១៩ ការលាតត្រដាងដែលបានតម្រូវដោយ កថាខណ្ឌ ១៨ ត្រូវបានធ្វើឡើងដាច់ដោយឡែកសម្រាប់ខ្នង់នីមួយៗដូចខាងក្រោម:

(ក) ក្រុមហ៊ុនមេ

(ខ) អង្គភាពជាមួយនឹងការគ្រប់គ្រងរួម ឬ ឥទ្ធិពលសំខាន់លើអង្គភាព

(គ) ក្រុមហ៊ុនបុត្រសម្ព័ន្ធ

(ឃ) ក្រុមហ៊ុនញាតិសម្ព័ន្ធ

(ង) ក្រុមហ៊ុនរួមទុនដែលអង្គភាពជាអ្នកចូលរួមទុន

(ច) បុគ្គលិកគ្រប់គ្រងសំខាន់របស់អង្គភាព ឬ ក្រុមហ៊ុនមេ និង

(ឆ) ភាគីពាក់ព័ន្ធផ្សេងទៀត។

២០ ការចាត់ថ្នាក់នៃទឹកប្រាក់ត្រូវសងទៅឱ្យ និងត្រូវទទួលពីភាគីពាក់ព័ន្ធនៅក្នុងខ្នង់ខុសគ្នា។ ដូចបានតម្រូវឱ្យមាននៅក្នុង កថាខណ្ឌ ១៩ គឺជាការបន្ថែមចំពោះសេចក្តីតម្រូវលើការលាតត្រដាងនៅក្នុង ស.គ.អ.ក ១ *ការបង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុ* សម្រាប់ព័ត៌មាន ដែលត្រូវដាក់បង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬនៅក្នុងកំណត់សម្គាល់។ ខ្នង់ត្រូវបានពង្រីកបន្ថែម ដើម្បីផ្តល់នូវការវិភាគ ដ៏ល្អិតល្អន់ច្រើនជាងមុន ពីសមតុល្យរបស់ភាគីពាក់ព័ន្ធនិងអនុវត្តចំពោះប្រតិបត្តិការនៃភាគីពាក់ព័ន្ធ។

២១ ខាងក្រោមនេះគឺជាឧទាហរណ៍នៃប្រតិបត្តិការដែលត្រូវបានលាតត្រដាង ប្រសិនបើប្រតិបត្តិការនោះជាមួយ ភាគីពាក់ព័ន្ធ:

(ក) ការទិញ ឬការលក់ទំនិញ (ផលិតរួច ឬ មិនទាន់ផលិតរួច)

(ខ) ការទិញ ឬការលក់ទ្រព្យ និងទ្រព្យសកម្មផ្សេងទៀត

(គ) ការផ្តល់ ឬទទួលសេវា

(ឃ) ភតិសន្យា

(ង) ការផ្ទេរនៃការស្រាវជ្រាវ និង ការអភិវឌ្ឍន៍

(ច) ការផ្ទេរក្រោមកិច្ចព្រមព្រៀងមានអជ្ញាបណ្ណ

(ឆ) ការផ្ទេរក្រោមការរៀបចំហិរញ្ញវត្ថុ (រួមបញ្ចូលទាំងកំចី និងការដាក់ទុនជាសាច់ប្រាក់ ឬសំភារៈ)

(ជ) ការផ្តល់ការធានា ឬវត្ថុដាក់ធានា

(ឈ) ការសន្យា ដើម្បីធ្វើអ្វីមួយ ប្រសិនបើព្រឹត្តិការណ៍ជាក់លាក់មួយកើតឡើង ឬមិនកើតឡើងនៅពេលអនាគត រួមបញ្ចូលទាំងកិច្ចសន្យាប្រតិបត្តិ* (ទទួលស្គាល់រួច និង មិនទាន់ទទួលស្គាល់) និង

(ញ) ការទូទាត់បំណុលជំនួសឱ្យអង្គភាព ឬដោយអង្គភាពជំនួសភាគីពាក់ព័ន្ធនោះ ។

២២ ការចូលរួម ដោយក្រុមហ៊ុនមេ ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ នៅក្នុងផែនការអត្ថប្រយោជន៍បានកំណត់ដែលចែក រំលែកនូវហានិភ័យ រវាងអង្គភាពដែលនៅក្នុងបណ្តុំក្រុមហ៊ុន គឺជាប្រតិបត្តិការមួយរវាងភាគីពាក់ព័ន្ធ (សូមមើលកថាខណ្ឌ ៣៨ខ នៃ ស.គ.អ.ក ១៩)។

២៣ ការលាតត្រដាង ដែលប្រតិបត្តិការភាគីពាក់ព័ន្ធ ត្រូវបានធ្វើឡើង តាមលក្ខខណ្ឌសមមូលចំពោះការលាតត្រដាង ដែលបង្ហាញនៅក្នុងប្រតិបត្តិការធម្មតាត្រូវបានធ្វើឡើងតែប្រសិនបើលក្ខខណ្ឌបែបនេះអាចមានភាពសំខាន់។

២៤ ធាតុដែលមានលក្ខណៈស្រដៀងគ្នាអាចត្រូវបានលាតត្រដាងនៅក្នុងទឹកប្រាក់រុបនៅពេលដែល ការលាតត្រដាងដាច់ដោយឡែកមានភាពចាំបាច់ដើម្បីយល់ដឹងពីឥទ្ធិពលនៃប្រតិបត្តិការរបស់ភាគី ពាក់ព័ន្ធនៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព។

២៥ អង្គភាពរាយការណ៍គឺត្រូវបានលើកលែងពីសេចក្តីតម្រូវសម្រាប់ការលាតត្រដាងនៃកថាខណ្ឌ ១៨ ដែលទាក់ទិន នឹងប្រតិបត្តិការភាគីពាក់ព័ន្ធ និងសមតុល្យនៅសល់ រួមបញ្ចូលទាំងការសន្យាជាមួយៈ

(ក) រដ្ឋាភិបាលដែលមានការគ្រប់គ្រង ការគ្រប់គ្រងរួម ឬមានឥទ្ធិពលសំខាន់លើអង្គភាពរាយការណ៍ និង (ខ) អង្គភាពមួយទៀត ដែលជាភាគីពាក់ព័ន្ធដោយសារតែរដ្ឋាភិបាលដដែលមានការគ្រប់គ្រង

ការគ្រប់គ្រងរួម ឬមានឥទ្ធិពលសំខាន់លើទាំងអង្គភាពរាយការណ៍ផង និង អង្គភាពផ្សេងទៀត។

២៦ ប្រសិនបើអង្គភាពរាយការណ៍ប្រើការលើកលែងនៅក្នុងកថាខណ្ឌ ២៥ អង្គភាពនោះត្រូវលាតត្រដាង នូវចំណុចខាងក្រោម ស្តីអំពីប្រតិបត្តិការ និងសមតុល្យទាក់ទិនដែលនៅសល់ដែលយោងទៅក្នុង កថាខណ្ឌ ២៥

(ក) ឈ្មោះរបស់រដ្ឋាភិបាល និងលក្ខណៈនៃទំនាក់ទំនងរបស់វាជាមួយនឹងអង្គភាពរាយការណ៍ (ពោលគឺ ការគ្រប់គ្រង ការគ្រប់គ្រងរួម និងឥទ្ធិពលសំខាន់)

(ខ) ព័ត៌មានខាងក្រោមដែលមានលក្ខណៈគ្រប់គ្រាន់ ដើម្បីផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពដើម្បីយល់ពីឥទ្ធិពលនៃប្រតិបត្តិការភាគីពាក់ព័ន្ធនៅលើរបាយការណ៍ហិរញ្ញវត្ថុៈ

(១) លក្ខណៈ និង ទឹកប្រាក់នៃប្រតិបត្តិការសំខាន់មួយៗ និង

(២) សម្រាប់ប្រតិបត្តិការផ្សេងទៀតដែលរួមគ្នា ប៉ុន្តែមិនមួយៗទេ ដែលបង្ហាញពីភាពសំខាន់ ភាពមានគុណភាព ឬ បរិមាណនៃទំហំរបស់គេ។ ប្រភេទប្រតិបត្តិការរួមបញ្ចូលនូវ ប្រភេទប្រតិបត្តិការដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ២១។

២៧ នៅក្នុងការប្រើប្រាស់ការវិនិច្ឆ័យ ដើម្បីកំណត់ពីកម្រិតនៃភាពលម្អិត ដែលត្រូវបានលាតត្រដាងដោយអនុលោម តាម២៦(ខ) អង្គភាពរាយការណ៍ត្រូវពិចារណាពីភាពជិតស្និទ្ធបំផុតនៃទំនាក់ទំនងរបស់ភាគីពាក់ព័ន្ធនិងកត្តាផ្សេងទៀត ដែលពាក់ព័ន្ធ ដែលទាក់ទិននឹងការបង្កើតកម្រិតនៃភាពសំខាន់របស់ប្រតិបត្តិការដូចជាថាតើវា:

(ក) សំខាន់នៅក្នុងលក្ខខណ្ឌទំហំដែរ ឬទេ

(ខ) ត្រូវបានអនុវត្តតាមលក្ខខណ្ឌមិនមែនទីផ្សារ

(គ) នៅខាងក្រៅកិច្ចប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃធម្មតារបស់អង្គភាពដូចជាការទិញ និងការលក់របស់អាជីវកម្ម

(ឃ) ត្រូវបានលាតត្រដាងចំពោះអាជ្ញាធរគ្រប់គ្រង និងអាជ្ញាធរច្បាប់

(ង) ត្រូវបានរាយការណ៍ទៅឱ្យគណៈគ្រប់គ្រងជាន់ខ្ពស់

(ច) ជាកម្មវត្ថុចំពោះការអនុម័តរបស់ម្ចាស់ភាគហ៊ុន។

កាលបរិច្ឆេទប្រសិទ្ធភាព និង អន្តរកាល

២៨ អង្គភាពមួយត្រូវអនុវត្តស្តង់ដានេះប្រតិសកម្ម សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទីឬបន្ទាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១១។ ការអនុវត្តមុនកាលកំណត់ត្រូវបានអនុញ្ញាតដោយការលើកលែងរបស់ស្តង់ដាទាំងមូល ឬការលើកលែងដោយផ្នែកនៅក្នុងកថាខណ្ឌ ២៥-២៧ សម្រាប់អង្គភាព ដែលទាក់ទិននឹងរដ្ឋាភិបាល។ ប្រសិនបើអង្គភាពមួយអនុវត្តការលើកលែងនៅក្នុងស្តង់ដាទាំងមូល ឬការលើកលែងដោយផ្នែក មុនថ្ងៃទី១ ខែមករា ឆ្នាំ ២០១១ អង្គភាពត្រូវលាតត្រដាងពីហេតុការណ៍នោះ។

ការដកចេញនៃ ស.គ.អ.ក ២៤ (២០០៣)

២៩ ស្តង់ដានេះជំនួសឱ្យ ស.គ.អ.ក ២៤ *ការលាតត្រដាងពីភាគីពាក់ព័ន្ធ* (ដូចបានកែប្រែនៅក្នុងឆ្នាំ ២០០៣)

ក្រុមប្រឹក្សាជាតិគណនេយ្យ

ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា

អាស័យដ្ឋាន: ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

អ៊ីម៉ែល: info@naccambodia.gov.kh | គេហទំព័រ: www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ